ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន

និង សង្គ្រោះជនពិការដោយសារមីន

លេខ: ✓ អន / អគម / ២០២៥

# សេចក្តីថ្លែងការណ៍

## អាជ្ញាធរមីនថ្កោលទោសចំពោះការប្រើប្រាស់គ្រាប់បែកចង្កោម ដោយយោធាថៃនៅតាមបណ្តោយព្រំដែនកម្ពុជា

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សម្តែងការព្រួយបារម្ភ និងថ្កោលទោសយ៉ាងខ្លាំងបំផុត បន្ទាប់ពីទទួលបានរបាយការណ៍ថា កងកម្លាំងប្រដាប់អាវុធថៃបានប្រើប្រាស់គ្រាប់បែកចង្កោមនៅថ្ងៃនេះ គឺថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ នៅតំបន់ព្រំដែនក្នុងទឹកដីកម្ពុជា។

តាមព័ត៌មានបឋមដែលទទួលបានពីអាជ្ញាធរមូលដ្ឋាន និងក្រុមបច្ចេកទេសបោសសម្អាតមីន បានបញ្ជាក់ច្បាស់ថា មានគ្រាប់ជាច្រើន ដែលមានលក្ខណៈដូចទៅនឹងគ្រាប់បែកចង្កោមដែលហាមប្រាមដោយអន្តរជាតិ ត្រូវបានប្រើប្រាស់ទៅលើទីតាំងភ្នំខ្មោច និងទីតាំងភូមិធម្មជាតិ ស្រុកជាំក្សាន្ត ដែលបង្កការគំរាមកំហែងចំពោះប្រជាជន ប្រតិបត្តិករបោសសម្អាតមីន និងសហគមន៍ក្នុងតំបន់ព្រំដែន។

ទង្វើនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់អន្តរជាតិ។ គ្រាប់បែកចង្កោមត្រូវ បានហាមប្រាមនៅក្រោមអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមឆ្នាំ២០០៨ ដោសារតែគ្រាប់នេះ បង្កផលប៉ះពាល់ទៅលើផ្ទៃដីធំ និងបង្កគ្រោះថ្នាក់ចំពោះប្រជាជន ជាពិសេសក្មេងតូច។ កម្ពុជា បានយល់ច្បាស់អំពីផលប៉ះពាល់ដ៏អាក្រក់របស់គ្រាប់ចង្កោម ដោយកម្ពុជាធ្លាប់ទទួលរងគ្រោះធ្ងន់ធ្ងរ ដោយសារគ្រាប់ប្រភេទនេះ ដែលបានទម្លាក់ជាច្រើនលានគ្រាប់នៅក្នុងសម័យសង្គ្រាម។ គ្រាប់បែកចង្កោមទាំងនេះ បានបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជនរារាំងការអភិវឌ្ឍ និងបង្កភាពភ័យក្លាយដល់សហគមន៍ជាច្រើនជំនាន់ទៅមុខ។

ការប្រើប្រាស់គ្រាប់បែកចង្កោមជាពិសេសនៅក្នុងតំបន់ព្រំដែនដែលមានប្រជាជនរស់នៅកកកុញ គឺជាទង្វើបំពានដែលមិនអាចទទួលយកបានឡើយ ព្រោះវាជាការមិនគោរពដល់អាយុជីវិតមនុស្ស គោលការណ៍មនុស្សធម៌ និងសន្តិភាពក្នុងតំបន់។ កម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការបោសសម្អាតរាល់សំណល់ជាតិផ្ទុះពីសង្គ្រាម ក៏ប៉ុន្តែ ការប្រើប្រាស់គ្រាប់បែកចង្កោមនៅថ្ងៃនេះ ពិតជាបានគំរាមកំហែងដល់អាយុជីវិត និងកិច្ចសហប្រតិបត្តិការ និងទំនុកចិត្ត ដែលបានសាងមកអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។

អាជ្ញាធរមីន សូមធ្វើការថ្កោលទោសជាខ្លាំងចំពោះទង្វើនេះ និងទាមទារឱ្យបញ្ឈប់ជាបន្ទាន់នូវការប្រើប្រាស់អាវុធប្រភេទនេះ។

ទង្វើនេះ កើតឡើងខណៈពេលដែលកម្ពុជា បាននិងកំពុងរក្សានូវភាពអត់ធ្មត់ជាអតិបរមា និងអនុលោមពេញលេញទៅតាមគោលការណ៍នៃអនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស។ អាជ្ញាធរមីន សូមរំលឹកដក់គ្រប់ភាគីផងដែរថា វឌ្ឍនភាពសកម្មភាពមីន និងសន្តិភាពក្នុងតំបន់ អាចសម្រេចបានតាមរយៈកិច្ចសន្ទនា ការគោរពគ្នាទៅវិញទៅមក និងការបដិសេធដាច់ខាតចំពោះអំពើហឹង្សា និងការប្រើប្រាស់កម្លាំងយោធា។

អាជ្ញាធរមីន សូមបញ្ជាក់ជាថ្មីនូវការប្ដេជ្ញាចិត្តរបស់ខ្លួនចំពោះតម្លាភាព និងគណនេយ្យភាព និងស្នើអញ្ជើញដល់សហគមន៍អន្តរជាតិ រួមទាំង អង្គការសហប្រជាជាតិ អាស៊ាន និងគ្រប់ស្ថាប័នពាក់ព័ន្ធទៅនឹងការរំសាយអាវុធមនុស្សធម៌ ចូលរួមតាមដានស្ថានការណ៍។

ថៃត្រូវតែបញ្ឈប់រាល់សកម្មភាពនេះជាបន្ទាន់និងត្រូវរក្សានូវគោលការណ៍ច្បាប់មនុស្សធម៌អន្តរជាតិតាមរយៈកិច្ចសន្ទនាដោយសន្តិវិធី។

របាយការណ៍បានបញ្ជាក់ថា នៅវេលាម៉ោង ០៥:២៥ នាទីព្រឹក យោធាថៃបានទម្លាក់គ្រាប់បែកចង្កោមនៅទីតាំងភ្នំខ្មោច នៅតាមបណ្ដោយព្រំដែនខេត្តព្រះវិហារ។ ការវាយប្រហារនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សហគមន៍ក្នុងតំបន់ព្រំដែន និងបំពានចំពោះច្បាប់អន្តរជាតិ។ ការវាយប្រហារលើកទីពីរគឺនៅវេលាម៉ោង ០៦:៥០ នាទីនៅទីតាំងភូមិតេជោធម្មជាតិ ស្រុកជាំក្សាន្ត ដែលបានគំរាមកំហែងដល់អាយុជីវិតប្រជាជននៅតាមតំបន់ព្រំដែន។

ថ្ងៃសុក្រ ១៥រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២៥

អាជ្ញាធរមីន
CMAA

KINGDOM OF CAMBODIA
Nation Religion King

THE ROYAL GOVERNMENT
Cambodian Mine Action
and Victim Assistance Authority

File No.: (Special)/CMAA/2025

**Press Release**

**CMAA Condemns Use of Cluster Munitions by Thai Forces Along the Cambodian Border**

The Cambodian Mine Action and Victim Assistance Authority (CMAA) expresses its deepest alarm and strongest condemnation following reports that the Royal Thai Armed Forces deployed cluster munitions today, July 25, 2025, in a border area within the Cambodian territory.

Preliminary information received from local authorities and technical demining teams confirms that multiple submunitions—consistent with internationally banned cluster munitions—were deployed in the vicinity of Phnom Khmouch and Techo Thammachart Village, posing an immediate and indiscriminate threat to civilians, deminers, and border communities.

This action constitutes a serious breach of international humanitarian norms. Cluster munitions are banned under the 2008 Convention on Cluster Munitions (CCM) due to their wide-area effect and the long-lasting danger they pose to civilians, particularly children. Cambodia knows all too well the horrific impact of cluster munitions, having endured the devastating legacy of millions of submunitions dropped on its land during past conflicts. These weapons have maimed civilians, obstructed development, and left entire communities in fear for generations.

Thailand is once again resorting to brutal tactics it employed in 2011 during the armed conflict with Cambodia near Preah Vihear Temple, when it used cluster munitions which resulted in widespread damages and contamination.

Senior Minister Ly Thuch, First Vice President of CMAA, stated: "the use of cluster munitions—especially in or near civilian-populated border areas—is an unacceptable escalation. It shows complete disregard for human life, humanitarian principles, and regional peace. Although Cambodia is not a state party to the Convention on Cluster Munitions, Cambodia has never used cluster munitions and has worked tirelessly to rid our country of these indiscriminate weapons. Today's incident threatens not only lives but decades of trust-building and cooperation."

CMAA condemns this reckless act and demands the immediate cessation of any further deployment of such weapons. This act comes at a time when Cambodia has been exercising maximum restraint and maintaining its full compliance with the Anti-Personnel Mine Ban Convention. CMAA reminds all parties that progress in mine action and regional peacebuilding can only be achieved through dialogue, mutual respect, and the absolute rejection of violence and militarized provocation.

CMAA reiterates its commitment to transparency and accountability and invites the international community—including the United Nations, ASEAN, and relevant humanitarian disarmament bodies—to closely monitor the situation.

Thailand must immediately cease all hostile actions and uphold the principles of international humanitarian law through peaceful dialogue.

According to initial field reports, at 5:25 AM, Thai forces launched a large number of cluster munitions targeting the area of Phnom Khmouch (Ghost Mountain), located along the border in Preah Vihear province. This strike endangered the surrounding communities and marked a serious violation of humanitarian norms. A second attack was launched at 6:50 AM on Techo Thammachart Village in Choam Ksant District, where cluster munitions were again deployed, further escalating the threat to civilian life and border security.

Contact: H.E. Mr. Tel Kallyan, Spokesperson

Cambodian Mine Action and Victim Assistance Authority (CMAA)

Email: kallyan@cmaa.gov.kh

Phone: 012 969 679

---

About CMAA:

The Cambodian Mine Action and Victim Assistance Authority is the national coordinating body for mine action in Cambodia. It oversees demining operations, victim assistance, mine risk education, and international cooperation under the Ottawa Convention.

The statement is provided for public awareness.

Phnom Penh, 25 July 2025

Address : New Building, St .273, Corner 516, Sangkat Toul Sangker, Khan Russey Keo, Phnom Penh, Tel : 023 885 941, 023 881 492